ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើត និងដាក់ឲ្យអនុវត្តចំណាយប្រតិបត្តិការអាទិភាព ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ

រាជរដ្ឋាភិបាលកម្ពុជា

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះមានគោលដៅបង្កើត និងដាក់ឲ្យអនុវត្តចំណាយប្រតិបត្តិការអាទិភាពក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ ស្របតាមគោលការណ៍សុខដុមនីយកម្ម ការតម្រឹម និងការកែតម្រូវ។

ជំពូកទី ២

គោលការណ៍នៃចំណាយប្រតិបត្តិការអាទិភាព

មាត្រា២.-

ចំណាយប្រតិបត្តិការអាទិភាព គឺជាចំណាយប្រតិបត្តិការសរុបសម្រាប់ផ្តល់ជូនមន្ត្រីរាជការដែលត្រូវបានជ្រើសរើសឲ្យបំពេញការងារ ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ។ ចំណាយប្រតិបត្តិការអាទិភាពនឹងត្រូវបញ្ចប់នៅពេលលទ្ធផលដែលបានគ្រោងទុកត្រូវបានសម្រេច ឬ គម្រោង ឬ កម្មវិធីសហប្រតិបត្តិការអភិវឌ្ឍត្រូវបានបញ្ចប់។

មាត្រា៣.-

ចំណាយប្រតិបត្តិការអាទិភាពមិនមែនជាប្រាក់បៀវត្ស ឬ ជាប្រាក់ឧបត្ថម្ភបន្ថែមលើបៀវត្សឡើយ ។

មាត្រា៤.-

ក្នុងការអនុវត្តគម្រោងសហប្រតិបត្តិការអភិវឌ្ឍ ដៃគូអភិវឌ្ឍមិនអាចផ្តល់ជូនមន្ត្រីរាជការនូវចំណាយប្រតិបត្តិការណាមួយ ក្រៅពីចំណាយប្រតិបត្តិការអាទិភាពនេះឡើយ លើកលែងតែមានការអនុញ្ញាតជាផ្លូវការពីរាជរដ្ឋាភិបាល។

ជំពូកទី ៣

កម្រិតចំណាយប្រតិបត្តិការអាទិភាព

មាត្រា៥.-

ចំណាយប្រតិបត្តិការអាទិភាពសរុបក្នុងមួយខែ ត្រូវអនុវត្តតាមកម្រិតដូចខាងក្រោម ៖
១. កម្រិតចំណាយប្រតិបត្តិការអាទិភាពសម្រាប់ថ្នាក់ជាតិឬសេវាទ្រទ្រង់ មាន ៖

- ចំណាយប្រតិបត្តិការការងារដឹកនាំកម្មវិធី
  ពី ១ ៤៧០ ០០០ រៀល ទៅ ១ ៦៨០ ០០០ រៀល

- ចំណាយប្រតិបត្តិការការងារគ្រប់គ្រងគម្រោង

  ពី ៨៤០ ០០០ រៀល ទៅ ១ ២៦០ ០០០ រៀល

- ចំណាយប្រតិបត្តិការការងារប្រតិបត្តិ

  ពី ៥០៤ ០០០ រៀល ទៅ ៧៥៦ ០០០ រៀល

២. កម្រិតចំណាយប្រតិបត្តិការអាទិភាពសម្រាប់ថ្នាក់ក្រោមជាតិឬសេវាជួរមុខ មាន ៖

- ចំណាយប្រតិបត្តិការការងារគ្រប់គ្រងគម្រោង

  ពី ៣៧៨ ០០០ រៀល ទៅ ៤៦២ ០០០ រៀល

- ចំណាយប្រតិបត្តិការការងារប្រតិបត្តិ

  ពី ២១០ ០០០ រៀល ទៅ ២៩៤ ០០០ រៀល

៣. កម្រិតចំណាយប្រតិបត្តិការអាទិភាពសម្រាប់អ្នកឯកទេសកម្រិតខ្ពស់ នឹងត្រូវកំណត់ដោយឡែក បន្ទាប់ពីមានការឯកភាពរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ។

ជំពូកទី ៤

នីតិវិធីនៃការដាក់ឲ្យដំណើរការចំណាយប្រតិបត្តិការអាទិភាព

មាត្រា៦.-

ការកំណត់មុខសញ្ញាមន្ត្រីរាជការសម្រាប់បំពេញការងារក្នុងក្របខ័ណ្ឌចំណាយប្រតិបត្តិការអាទិភាព ត្រូវធ្វើឡើងដោយមានតម្លាភាព ផ្អែកលើលក្ខខណ្ឌយោង លក្ខណសម្បត្តិសក្តិសម មានសមធម៌ និងមាននីតិវិធី និងបែបបទច្បាស់លាស់ ។

មាត្រា៧.-

នីតិវិធីនិងបែបបទនៃការដាក់ឲ្យដំណើរការចំណាយប្រតិបត្តិការអាទិភាព ត្រូវកំណត់ក្នុងឯកសារណែនាំស្តីពីការអនុវត្តចំណាយប្រតិបត្តិការអាទិភាព ដែលរៀបចំដោយគណៈកម្មាធិការដឹកនាំការងារដើម្បីពិនិត្យ និងដោះស្រាយបញ្ហាប្រាក់ឧបត្ថម្ភបន្ថែមក្នុងក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ដោយមានការពិភាក្សាជាមួយដៃគូអភិវឌ្ឍ។

មាត្រា៨.-

ចំណាយប្រតិបត្តិការអាទិភាព ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

មាត្រា៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា១០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ